ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា

**នាយឧត្តមសេនីយ៍ មាស សាវ៉ន**
**អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា**
**ផ្ញើជូន**
**ឯកឧត្តម នាយឧត្តមសេនីយ៍កិត្តិបណ្ឌិត ហ៊ីង ប៊ុនហៀង អគ្គមេបញ្ជាការរង**
**និងជាមេបញ្ជាការ បញ្ជាការដ្ឋានអង្គរក្ស និងលោកជំទាវ**

*ឯកឧត្តម លោកជំទាវ ជាទីរាប់អាន*

ភរិយាខ្ញុំ និងរូបខ្ញុំ បានទទួលដំណឹងដ៏ក្រៀមក្រំអំពីមហាឧបាសិកា **តាត់ ឡឹង** ដែលត្រូវជាម្តាយបង្កើត និងម្តាយក្មេក របស់ឯកឧត្តម និងលោកជំទាវ បានទទួលមរណភាព នៅវេលាម៉ោង១៤:៤៥នាទី ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ ក្នុងជន្មាយុ ៨៨ឆ្នាំ ដោយជរាពាធ។

មរណភាពរបស់មហាឧបាសិកា **តាត់ ឡឹង** គឺជាការបាត់បង់មាតា ដ៏ដូន ប្រកបដោយព្រហ្មវិហារធម៌ ដែលមានទឹកចិត្តស្រឡាញ់កូនបំផុតអស់ពីចិត្តពីថ្លើម ហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីកូនចៅ និងជាការបាត់បង់កុលធីតាខ្មែរមួយរូបធ្លាប់មានស្នាដៃ និងគុណបំណាច់ដ៏ធំធេង ដែលបានរួមចំណែកក្នុងការងារមនុស្សធម៌ និងកិច្ចការសង្គមដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រ ព្រមទាំងជាឧបាសិកាគឺជាពុទ្ធសាសនិកមួយរូបដែលបានរួមចំណែកយ៉ាងសំខាន់ដល់វិស័យព្រះពុទ្ធសាសនានៅកម្ពុជា។

ក្នុងឱកាសមានទុក្ខដ៏ក្រៀមក្រំនេះ ភរិយាខ្ញុំ និងរូបខ្ញុំ សូមចូលរួមរំលែកទុក្ខនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយឯកឧត្តម លោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូន កូនចៅទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងឲ្យដួងវិញ្ញាណក្ខន្ធមហាឧបាសិកា **តាត់ ឡឹង** បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តម និងលោកជំទាវ ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

**មាស សាវ៉ន**